**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុប្បយោគផ្ទៃដីទំហំ ២៦២,២៤ (ពីររយហុកសិបពីរក្បៀសម្ភៃបួន)ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រភូមិពោធិ៍មាស ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនក្រុមគ្រួសារយោធិនបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងប្រជាពលរដ្ឋសរុបចំនួន ៤១គ្រួសារ សម្រាប់សាងសង់លំនៅដ្ឋាន និងបង្កបង្កើនផល ស្របច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស0/រកត/៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងលិខិតលេខ ៧៤០ សណ.បស្ថ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងបរិស្ថាន

**សម្រេច**

**មាត្រា១ ._**

ត្រូវបានធ្វើអនុប្បយោគផ្ទៃដីទំហំ ២៦២,២៤ (ពីររយហុកសិបពីរក្បៀសម្ភៃបួន)ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រភូមិពោធិ៍មាស ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនក្រុមគ្រួសារយោធិនបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងប្រជាពលរដ្ឋសរុបចំនួន ៨១គ្រួសារ សម្រាប់សាងសង់លំនៅដ្ឋាន និងបង្កបង្កើនផលស្របច្បាប់ ដែលមានផែនទី និងចំណុចនិយាមកា (Datum: WGS1984 Zone48N) ភ្ជាប់នៃលិខិតលេខ ៧៤០ សណ.បស្ថ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងបរិស្ថាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដូចខាងក្រោម÷

| និយាមកាគោល | | | | | |
|---|---|---|---|---|---|
| ID | X | Y | ID | X | Y |
| 1 | 404079 | 1310890 | 13 | 402491 | 1311914 |
| 2 | 403858 | 1310973 | 14 | 402604 | 1311929 |
| 3 | 403822 | 1310793 | 15 | 402686 | 1311912 |
| 4 | 403136 | 1311101 | 16 | 402913 | 1311797 |
| 5 | 402728 | 1310873 | 17 | 403388 | 1311685 |
| 6 | 403003 | 1309989 | 18 | 403427 | 1311679 |
| 7 | 401966 | 1310016 | 19 | 403444 | 1311751 |
| 8 | 401961 | 1310921 | 20 | 403591 | 1311705 |
| 9 | 402067 | 1311212 | 21 | 403819 | 1311716 |
| 10 | 401897 | 1311408 | 22 | 404199 | 1311691 |
| 11 | 401962 | 1311704 | 23 | 404124 | 1311347 |
| 12 | 402339 | 1311876 | | | |

**មាត្រា២._**

ត្រូវបានប្រគល់អាណេត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ក្នុងការស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនក្រុមគ្រួសារយោធិនបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក និងប្រជាពលរដ្ឋសរុបចំនួន ៨១គ្រួសារ។

**មាត្រា៣._**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវរៀបចំបោះបង្គោលព្រំដី ដែលបានធ្វើអនុប្បយោគ ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ និងអនុវត្តការចុះបញ្ជីដី រួចលើកសំណើសុំផ្តល់សិទ្ធិលើក្បាលដី តាមគោលការណ៍ និងនីតិវិធីជាធរមាន។

**មាត្រា៤._**

ក្រសួងបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងផ្ទៃដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ឡើងវិញ ក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ឱ្យស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ផែនទី ស្តីពីការធ្វើអនុប្បយោគផ្លាស់ប្តូរចំណាត់ថ្នាក់ពីដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវដីទំហំ២៦២,២៤ហិកតា ស្ថិតនៅដែនជម្រកសត្វព្រៃ ភ្នំឱរ៉ាល់ ក្នុងភូមិសាស្រ្ត ភូមិពោធិ៍មាស ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនក្រុមគ្រួសារយោធិនបញ្ហាការដ្ឋានវេស្រោះកងទ័ពជើងគោកនិងប្រជាពលរដ្ឋសរុបចំនួន៤១គ្រួសារ សម្រាប់សាងសង់លំនៅដ្ឋាននិងបង្កបង្កើនផលស្របច្បាប់**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...១៤៨......អនក្រ.បក ចុះថ្ងៃទី..២០...ខែ..សីហា....ឆ្នាំ២០២១




| Id | X_Coor | Y_Coor |
|---|---|---|
| 1 | 404079 | 1310890 |
| 2 | 403858 | 1310973 |
| 3 | 403822 | 1310793 |
| 4 | 403136 | 1311101 |
| 5 | 402728 | 1310873 |
| 6 | 403003 | 1309989 |
| 7 | 401966 | 1310016 |
| 8 | 401961 | 1310921 |
| 9 | 402067 | 1311212 |
| 10 | 401897 | 1311408 |
| 11 | 401962 | 1311704 |
| 12 | 402339 | 1311876 |
| 13 | 402491 | 1311914 |
| 14 | 402604 | 1311929 |
| 15 | 402686 | 1311912 |
| 16 | 402913 | 1311797 |
| 17 | 403388 | 1311685 |
| 18 | 403427 | 1311679 |
| 19 | 403444 | 1311751 |
| 20 | 403591 | 1311705 |
| 21 | 403819 | 1311716 |
| 22 | 404199 | 1311691 |
| 23 | 404124 | 1311347 |

ថ្ងៃ ... ខែ ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០២១

**អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ**

ឡឹ សំណាង

ថ្ងៃ ... ខែ ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ចុះថ្ងៃទី ០១ ខែ ... ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

សាយ សំអាល់

**តំណាងសំគាល់**

- ផ្លូវ
- ផ្លូវ
- ព្រំប្រទល់ស្រុក
- ស្នាក់ការ...
- ដីស្នើសុំអនុប្បយោគ
- ដែនជម្រកសត្វព្រៃ

ប្រភពទិន្នន័យ: រដ្ឋបាលព្រៃឈើ...